


# បទសរភញ្ញ

**ព្រះរាជនិពន្ធដោយសម្ដេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ជួន ណាត**
**ព្រះសង្ឃរាជ គណៈមហានិកាយ និងជាបិតាអក្សរសាស្ត្រខ្មែរ**
ថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥០៨
ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ គ.ស.១៩៦៥

សូមថ្វាយបង្គំ ព្រះសម្ពុទ្ធ ប្រសើរបំផុត ក្នុងលោកា
ជាគ្រូនៃមនុស្ស និងទេវតា ទ្រង់ត្រាស់ទេសនា ប្រដៅសត្វ ។
ចង្អុល ឱ្យដើរ ផ្លូវកណ្ដាល មាគ៌ាត្រកាល អាចកម្ចាត់
ទុក្ខភ័យចង្រៃ ឱ្យខ្ចាយបាត់ អាចកាត់សង្សារៈទុក្ខបាន ។
សាសនាព្រះអង្គ នៅសព្វថ្ងៃ សត្វមាននិស្ស័យ ពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ ចេះចាំបាន កាន់តាមលំអាន បានក្ដីសុខ ។
ឥតមានសុខណា ស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខ ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ តទៅមុខ ក្ដីសុខនឹងមាន ព្រោះធម៌ស្ងប់ ។
សូមថ្វាយបង្គំ ឆ្ពោះព្រះធម៌ ព្រះសង្ឃបវរ ទាំងសព្វគ្រប់
រួមជាត្រៃរ័ត្ន គួរគោរព ជាម្លប់ត្រជាក់ នៃលោកា ។
ព្រះរូបព្រះធាតុ នៃព្រះពុទ្ធ វិសុទ្ធិតាងអង្គ ព្រះសាស្ដា
សូមគុណត្រៃរ័ត្ន ជួយខេមរា ឱ្យបានសុខា តរៀងទៅ ។

វត្តគិរីវង្សាបុប្ផារាម អាស្រមសមាធិសន្តិភាព
ថ្ងៃព្រហស្បតិ៍ ១៣កើត ខែអាសាធ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា គ.ស.២០១៧
ទីក្រុងឡេវវីរ៉េត រដ្ឋម៉ាសាឈូសិត្តស៍ សហរដ្ឋអាមេរិក
៤១៣.៣៦៧.២០២៨; អាសយដ្ឋានអ៊ីមែល: vipassanadhura@gmail.com